**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបន្ថែមឥណទានថវិកា

## ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣· ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៦.០៦៨.០០០.០០០ រៀល ( ប្រាំមួយពាន់ ហុកសិបប្រាំបីលានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ឥណទានថវិកាបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ផ្តល់ជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត សៀមរាប សំរាប់បើកបៀវត្សជូន ជនពាត់បង់សមត្ថភាពការងារ ជនពិការ និង និវត្តជន ដែលជាយោធិនរំសាយពីក្រសួងការពារជាតិ ។

**មាត្រា៣:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

[illegible] ទីមុល

រដ្ឋមន្ត្រីស្តីទី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- កាលប្បវត្តិ - ឯកសារ